ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

តុលាការកំពូល

សាធារណ៍ព្រហ្មទណ្ឌ

សំណុំរឿងព្រហ្មទណ្ឌ

លេខ ១៩៨

ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧

សាលដីកា

លេខ ០៣ "II"

ចុះថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០

# សាលដីកា

## នាមប្រជារាស្ត្រខ្មែរ

## តុលាការកំពូល

បានបើកសវនាការជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០

ដោយអង្គជំនុំជម្រះមានសមាសភាពចៅក្រមដូចខាងក្រោម ៖

១. លោកស្រី [redacted] ជាប្រធាន

២. លោក [redacted] ជាចៅក្រម

៣. លោក [redacted] ជាចៅក្រម

៤. លោក [redacted] ជាចៅក្រម

៥. លោក [redacted] ជាចៅក្រម

## ក្រឡាបញ្ជីសវនាការ

លោក [redacted]

## តំណាងមហាអយ្យការ

លោក [redacted] ឋានៈជាព្រះរាជអាជ្ញា

## ដើម្បីជំនុំជម្រះ

លើបណ្តឹងសាទុក្ខលេខ ២៤២ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ចំពោះសាលដីកាព្រហ្មទណ្ឌលេខ ១៦ ក្រIV "វ" ចុះថ្ងៃទី១៥ ខែសីហា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ដែលមាន ៖

- **ជនជាប់ចោទ** ៖ ឈ្មោះ [redacted] ឌី ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកន្ទ្រក សង្កាត់លេខ២ ទីរួមខេត្តសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅភូមិកន្ទ្រក [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ អែម "រ" ទោសពីមុនគ្មាន។ (នៅក្រៅឃុំ) (អ្នកប្តឹងសាទុក្ខ)



Scanned with CamScanner

- **ជាប់ចោទពីបទ** ជេរប្រមាថជាសាធារណៈ និងធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិកន្ត្រក សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣០៧ និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

- **ដើមបណ្តឹងរដ្ឋប្បវេណី** ៖ ឈ្មោះ [redacted]វ៉ាន់ ភេទស្រី អាយុ ៤៧ឆ្នាំ ជាតិខ្មែរ ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប។

**អំពីអង្គហេតុ**

កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ ឈ្មោះ [redacted] ឌី ត្រូវជាកូនប្រសារមានទំនាស់ជាមួយម្តាយក្មេកឈ្មោះ [redacted]វ៉ាន់ ហើយបានកាប់បំផ្លាញបេងលួស ខូចខាតចំនួន ០៣ខ្សែ ពេលនោះឈ្មោះ [redacted]វ៉ាន់ ទៅសួរនាំឈ្មោះ [redacted] ឌី បានជេរប្រមាថយ៉ាងខ្លាំងទៅលើឈ្មោះ [redacted]វ៉ាន់ ។

សាលាដំបូងខេត្តសៀមរាប បានសម្រេចតាមអំណាចសាលក្រមព្រហ្មទណ្ឌលេខ ៤៧ "គ" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៤ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១-ផ្តន្ទាទោសឈ្មោះ [redacted] ឌី ភេទប្រុស អាយុ ២៩ឆ្នាំ ជាតិខ្មែរ ទីកន្លែងកំណើតនៅភូមិកន្ត្រក សង្កាត់លេខ ២ ទីរួមខេត្តសៀមរាប ខេត្តសៀមរាប ទីលំនៅបច្ចុប្បន្ននៅ [redacted] ខេត្តសៀមរាប ឪពុកឈ្មោះ [redacted] "រ" ម្តាយឈ្មោះ អែម "រ" ទោសពីមុនគ្មាន ដាក់ពន្ធនាគារកំណត់រយៈពេល ០១ (មួយ)ឆ្នាំ។

ពីបទ ជេរប្រមាថជាសាធារណៈ និងធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិកន្ត្រក សង្កាត់ស្វាយដង្គុំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា ៣០៧ និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌ។

២-ឱ្យឈ្មោះ [redacted] ឌី សងសំណងការខូចខាតទៅឱ្យដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វ៉ាន់ ចំនួន ៤.000.000 (បួនលាន)រៀល ការទាមទារលើសពីនេះ ត្រូវបដិសេធចោល។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី១៨ ខែកញ្ញា ឆ្នាំ២០១៤ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វ៉ាន់, កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ឌី និងបើកផ្លូវប្តឹងទាស់ និងប្តឹងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

សាលក្រមនេះត្រូវបានឈ្មោះ [redacted] ឌី ប្តឹងឧទ្ធរណ៍តាមបណ្តឹងលេខ ២៥ ចុះថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៥ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។



Scanned with CamScanner

សាលាឧទ្ធរណ៍បានសម្រេចតាមអំណាចសាលដីកាព្រហ្មទណ្ឌលេខ ១៦ ក្រIV "រ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ ដែលមានខ្លឹមសារ នៃសេចក្តីសម្រេចដូចតទៅ ៖

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៥ របស់ឈ្មោះ [redacted]ឌី ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយទាស់នឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៤៧ "គ" ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០១៤ របស់សាលាដំបូងខេត្តសៀមរាប ទុកជាបានការដដែល។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៩ ខែមីនា ឆ្នាំ២០១៧ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted]ឌី និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted]វ៉ាន់ និងប្រកាសជាសាធារណៈនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧។

-ទុកសិទ្ធិប្តឹងទាស់ និងប្តឹងសាទុក្ខក្នុងកំណត់ច្បាប់។

សាលដីកានេះត្រូវបានឈ្មោះ [redacted]ឌី ប្តឹងសាទុក្ខតាមបណ្តឹងលេខ ២៤២ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល។

## នាពេលសវនាការ

-ចៅក្រមរបាយការណ៍បានអានរបាយការណ៍

-តំណាងមហាអយ្យការអមតុលាការកំពូលបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទឈ្មោះ [redacted]ឌី បានប្តឹងសាទុក្ខមកតុលាការកំពូល ក៏ប៉ុន្តែមិនបានដាក់សារណាការពារមកតុលាការកំពូលទេ។ ហេតុដូចនេះ ចាប់ទុកថាបណ្តឹងសាទុក្ខរបស់ជនជាប់ចោទគ្មានមូលហេតុដូចមានកំណត់នៅក្នុងមាត្រា ៤១៩ និងមាត្រា ៤៣៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌនោះទេ។ តំណាងមហាអយ្យការស្នើសុំតម្កល់សាលដីកាព្រហ្មទណ្ឌរបស់សាលាឧទ្ធរណ៍ ទុកជាបានការដដែល។

## តុលាការកំពូល

- ក្រោយពីបានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍
- ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ
- ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ។

## សំអាងហេតុ

១-យល់ឃើញថា បណ្តឹងសាទុក្ខលេខ ២៤២ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted]ឌី ធ្វើឡើងក្នុងកំណត់ច្បាប់ យោងតាមមាត្រា ៦៤ នៃច្បាប់ស្តីពីការរៀបចំអង្គការតុលាការ និងមាត្រា ៤២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តុលាការកំពូលអាចលើកយករឿងនេះមកជំនុំជម្រះបាន។



Scanned with CamScanner

២-យល់ឃើញថា តុលាការកំពូលបានធ្វើការជូនដំណឹងដល់ជនជាប់ចោទដែលជាម្ចាស់បណ្តឹងសាទុក្ខឱ្យដាក់សារណាការពារមូលហេតុនៃបណ្តឹងសាទុក្ខតាមលិខិតចុះថ្ងៃទី០៧ ខែកញ្ញា ឆ្នាំ២០១៧ ស្របតាមមាត្រា ៤២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌរួចហើយ ក៏ប៉ុន្តែ ម្ចាស់បណ្តឹងសាទុក្ខពុំបានដាក់សារណាការពារ តាមការបង្គាប់នេះទេ។

៣-យល់ឃើញថា តុលាការអង្គសេចក្តី ដែលបានប្រកាសទោសលើជនជាប់ចោទឈ្មោះ [redacted] ឌី ពីបទជេរប្រមាថជាសាធារណៈ និងពីបទ ធ្វើឱ្យខូចខាតដោយចេតនា ប្រព្រឹត្តនៅភូមិកន្ទ្រក សង្កាត់ស្វាយដង្គំ ក្រុងសៀមរាប ខេត្តសៀមរាប កាលពីថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៣ តាមមាត្រា ៣០៧ និងមាត្រា ៤១០ នៃក្រមព្រហ្មទណ្ឌនោះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ។

៤-យល់ឃើញថា តាមខ្លឹមសារនៃមាត្រា ៣០៧ នៃក្រមព្រហ្មទណ្ឌ ការផ្តន្ទាទោស ត្រូវពិន័យជាប្រាក់ចំនួន ១០០.០០០ រៀល ដល់ ១០ លានរៀល។ ដូច្នេះ ការដែលតុលាការអង្គសេចក្តីផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១ឆ្នាំ ពីបទចោទ បទជេរប្រមាថជាសាធារណៈ និងបទធ្វើឱ្យខូចខាតដោយចេតនា បញ្ចូលគ្នានោះ ជាការមិនត្រឹមត្រូវទេ។

៥-យល់ឃើញថា តុលាការអង្គសេចក្តីបានសម្រេចបង្គាប់ឱ្យជនជាប់ចោទសងសំណងការខូចខាតចំនួន ៤ លានរៀល ឱ្យទៅដើមបណ្តឹង ដោយសំអាងហេតុថា តុលាការនឹងសម្រេចអំពីសំណងនេះតាមច្បាប់ នោះជាការសម្រេចដោយគ្មានសំអាងហេតុ។

៦-យល់ឃើញថា សាលដីកាព្រហ្មទណ្ឌ ១៦ ក្រIV "វ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះត្រឹមត្រូវតាមច្បាប់ខ្លះ ខុសខ្លះ។

**ហេតុដូច្នេះ**

**វិនិច្ឆ័យសេចក្តី**

១. ទទួលផ្នែកខ្លះនៃបណ្តឹងសាទុក្ខលេខ ២៤២ ចុះថ្ងៃទី០៩ ខែសីហា ឆ្នាំ២០១៧ របស់ជនជាប់ចោទឈ្មោះ [redacted] ឌី ។

២. តម្កល់សាលដីកាព្រហ្មទណ្ឌលេខ ១៦ ក្រIV "វ" ចុះថ្ងៃទី១៥ ខែមីនា ឆ្នាំ២០១៧ របស់សាលាឧទ្ធរណ៍ ទុកជាបានការ លើកលែងតែទណ្ឌកម្ម និងទឹកប្រាក់សំណងចំនួន ៤ លានរៀលត្រូវបដិសេធចោល។

៣. បញ្ជូនសំណុំរឿងព្រហ្មទណ្ឌលេខ ១៩៨ ចុះថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៧ របស់តុលាការកំពូលទៅ សាលាឧទ្ធរណ៍ ដើម្បីជំនុំជម្រះជាថ្មីឡើងវិញ លើចំណុចទណ្ឌកម្ម និងទឹកប្រាក់សំណងការខូចខាត។



Scanned with CamScanner

សាលដីកានេះ បានជំនុំជម្រះជាសាធារណៈនៅថ្ងៃទី០៨ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈនៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០២០។

Scanned with CamScanner